អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (IUCN) បានបង្កើតឡើងនៅឆ្នាំ ១៩៤៨ ។ បេសកកម្មរបស់ខ្លួន គឺធ្វើអោយមានឥទ្ធិពលជំរុញទឹកចិត្ត និងជួយសង្គមនៅលើពិភពលោក ដើម្បីអភិរក្សបូរណភាព និងភាពចម្រុះនៃធម្មជាតិ និងដើម្បីធានាថាការប្រើប្រាស់ណាមួយនៃធនធានធម្មជាតិត្រូវមានសមភាព និងនិរន្តរភាពអេកូឡូស៊ី ។ អង្គការ IUCN ជាអង្គការមួយដែលមានសមាជិកភាពចូលរួម ហើយសមាជិករបស់អង្គការរួមមាន ៨២ជារដ្ឋ ១១២ជាភ្នាក់ងាររដ្ឋាភិបាល ៨០០ជាអង្គការក្រៅរដ្ឋាភិបាល និង៤០ចូលរួមទំនាក់ទំនង ហើយមានអ្នកវិទ្យាសាស្រ្ត និងអ្នកជំនាញការចំនួនជាង ១០.០០០ នាក់ មកពីបណ្តាប្រទេស ១៨១ លើពិភពលោក ។

**ពត៌មានលំអិតសូមមើលគេហទំព័រ** http: //www.iucn.org

# ការវាយតម្លៃចម្រុះតំបន់ដីសើមនៅកម្ពុជា

## បទពិសោធន៍ពីតំបន់រាមសារខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា

រៀបរៀងដោយ ដេវីដ អាលេន គង់ គីមស្រេង វីលៀម ដារ៉ល និង អូលីវើ ស្ព្រីងហ្គេតបាហ្គីនស្គី



ការិយាល័យអង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ ប្រចាំប្រទេសកម្ពុជា

អនុសាសន៍គោលនយោបាយសង្ខេប ទី២




Fig. 2: Informing Integrated Conservation and Development (ICAD) through integrated assessment (Source: Darwin Toolkit).

## PROPOSED APPLICATION OF THE TOOLKIT IN CAMBODIA

The Darwin Initiative offers post-project funding to a small number of successful projects "to maximise the results of these projects and strengthen their long-term impact and legacy". We are looking to further promote wetland assessment and management in Cambodia through an application for post-project funding to support a 1-year project Integrated wetland assessment for improved policy and practice: Scaling up implementation of the Darwin Toolkit process in Cambodia.

If successful, we will work with NGOs and responsible government departments to develop capacity in Cambodia to undertake integrated wetland assessment, and to conduct further integrated assessments of high priority wetland sites in Cambodia.

## INTERNATIONAL UNION FOR CONSERVATION OF NATURE

**The IWA Toolkit will be available in December 2008. For more information on the Stung Treng integrated assessment or the Darwin Initiative project please contact:**


| | |
|---|---|
| **Mr. Kong Kim Sreng**<br>Darwin Project Officer, IUCN Cambodia<br>#19 Street 312, Tonle Basac, Chamca Mon<br>P.O. Box: 1504 Phnom Penh<br>Cambodia<br>Tel: +855 (023) 222 311<br>Fax: +855 (023) 222 312<br>E-mail: kksreng@iucncambodia.org | **Dr. William Darwall**<br>Manager, Freshwater Biodiversity Unit<br>IUCN Species Programme<br>219c Huntingdon Road<br>Cambridge CB3 0DL<br>UK<br>Tel: +44 1223 277966<br>Fax: +44 1223 277845<br>E-mail: william.darwall@iucn.org |




***គម្រោងនេះបានទទួលមូលនិធិពីរដ្ឋាភិបាលចក្រភពអង់គ្លេស តាមរយៈ កិច្ចផ្តួចផ្តើម Darwin Initiative ដែលផ្អែកលើជំនាញខាងផ្នែកជីវៈចម្រុះនៅក្នុងចក្រភពអង់គ្លេស ដើម្បីជួយការពារ និងបង្កើនជីវៈចម្រុះនៅជុំវិញពិភពលោក។***

តំបន់ដីសើមមានគុណតម្លៃប្លែកៗ និងសាំញ៉ាំខាងផ្នែកជីវៈចម្រុះ និងសេដ្ឋកិច្ចសង្គម ដែលច្រើនតែពុំសូវឆ្លុះបញ្ចាំងបានត្រឹមត្រូវនៅក្នុងការអភិរក្ស និងការកសាងផែនការអភិវឌ្ឍន៏ឡើយ។ កិច្ចប្រឹងប្រែងនានាដើម្បីសម្រេចឱ្យបាននូវការអភិរក្ស និងគ្រប់គ្រងតំបន់ដីសើមឱ្យមាន និរន្តរភាពប្រសិទ្ធិភាព និងដោយសមធម៌មិអាចពង្រឹងទៅបានតាមរយៈការស្វែងយល់បានហ្មត់ចត់អំពីទំនាក់ទំនងរវាងជីវៈចម្រុះ ទិដ្ឋភាពសេដ្ឋកិច្ច និងការចិញ្ចឹមជីវិតនៅក្នុងតំបន់ដីសើម។ ប្រការនេះទាមទារឱ្យការវាយតម្លៃតំបន់ដីសើមដាក់បញ្ចូលទិដ្ឋភាពទាំងនេះតាមវិធីចម្រុះ។ បើទោះជាមានបច្ចេកទេសសម្រាប់វាយតម្លៃ អំពីជីវៈចម្រុះសេដ្ឋកិច្ច និង ការចិញ្ចឹមជីវិតនៅដាច់ដោយឡែកពីគ្នាក៏ដោយគេនៅខ្វះវិធីជាក់ស្តែងសម្រាប់ដាក់បញ្ចូលការវាយតម្លៃដាច់ដោយឡែកពីគ្នាទាំងនោះ ឬ បង្ហាញព័ត៌មានទាំងនេះ តាមវិធីដែលរួមចំណែកដល់ការអភិរក្ស និង ការកសាងផែនការអភិវឌ្ឍន៏ជាក់ស្តែង។

**IUCN** (អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ) និងដៃគូរបស់ខ្លួន បានធ្វើការវាយតម្លៃចម្រុះអំពីគុណតម្លៃខាងសេដ្ឋកិច្ចជីវៈចម្រុះ និងការចិញ្ចឹមជីវិតនៅតំបន់ដីសើមរ៉ាមសារក្នុងខេត្តស្ទឹងត្រែងនៅទន្លេមេគង្គក្រោមប្រទេសកម្ពុជា។ ការវាយតម្លៃនេះ មានគោលដៅប្រមូលទិន្នន័យពាក់ព័ន្ធអំពីជីវៈចម្រុះ និងសេដ្ឋ កិច្ចសង្គមដើម្បីដាក់បញ្ចូលទៅក្នុងដំណើរការកសាងផែនការគ្រប់គ្រងទីតាំងតំបន់រ៉ាមសារដែលបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា។ ការវាយតម្លៃនោះបានធ្វើឡើងជាផ្នែកមួយនៃគម្រោងអន្តរជាតិស្តីពីការពង្រឹងកិច្ចការអភិរក្សតំបន់ដីសើមដើម្បីកាត់បន្ថយភាពក្រីក្រ តាមរយៈការវាយតម្លៃចម្រុះអំពីជីវៈចម្រុះ និងការចិញ្ចឹមជីវិត ដែលបានចាប់ផ្តើមនៅក្នុងខែ តុលា ឆ្នាំ ២០០៥ និងបានបញ្ចប់នៅខែ ធ្នូ ឆ្នាំ២០០៨។ គម្រោងនេះបានទទួលមូលនិធិពីកិច្ចផ្តួចផ្តើម Darwin របស់ចក្រភពអង់គ្លេស ដោយមានគោលដៅរៀបចំ និងសាកល្បងឯកសារណែនាំសម្រាប់ការវាយតម្លៃចម្រុះតំបន់ដីសើមតាមរយៈពហុជំនាញ។

## ការវាយតម្លៃចម្រុះទីតាំងតំបន់រ៉ាមសារក្នុងខេត្តស្ទឹងត្រែង

នៅក្រោយហូរចាក់ចូលមកក្នុងប្រទេសកម្ពុជាតាមល្បាក់ខោន នៅក្នុងប្រទេសឡាវ ទន្លេមេគង្គបម្លែងទៅជាផ្លូវទឹកតូចៗជាច្រើន ដែលផ្សំដោយព្រៃលិចទឹកប្លែកពីគេព្រៃគម្ពោធ កោះ ឆ្នេរខ្សាច់ និងគ្រួស ទឹកជ្រូរ ទឹកកួច និងអន្លង់ជ្រៅៗ។ ការកំណត់ជាតំបន់ដីសើមរ៉ាមសារ ដែលមានសារៈសំខាន់ជាអន្តរជាតិ នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៩ ដោយសារតំបន់នេះជាជម្រកនៃប្រភេទសត្វ និងរុក្ខជាតិជាច្រើនដែលត្រូវបានកត់ត្រានៅក្នុងបញ្ជីក្រហម **IUCN**[1] ថាជាប្រភេទរងការគំរាមកំហែង ដែលរួមទាំងត្រយ៉ងចំកំកស រំពេទន្លេ ក្រពើត្រី ត្រីជាច្រើន ប្រភេទ និងសត្វផ្សោតទន្លេមេគង្គអ៊ីរ៉ាវ៉ាឌីផងដែរ។

នៅឆ្នាំ ២០០៦ ការសិក្សាវាយតម្លៃទិដ្ឋភាពអេកូឡូស៊ីនៅតំបន់រ៉ាមសារស្ទឹងត្រែង បាននាំឱ្យមានសំណើបង្កើតផែនការកំណត់តំបន់គ្រប់គ្រងសម្រាប់ទីតាំងនោះ ដែលរួមបញ្ចូលតំបន់ស្នូលមួយចំនួនដែលការនេសាទ និងសកម្មភាពផ្សេងទៀតរបស់សហគមន៏មូលដ្ឋាននឹងត្រូវហាមឃាត់។ អនុសាសន៏ទាំងនោះ ផ្អែកជាសំខាន់លើទស្សនៈវិស័យអំពីការអភិរក្សជីវៈចម្រុះ ដែលសន្និដ្ឋានថា សព្វថ្ងៃនេះប្រជាជនមូលដ្ឋានប្រើប្រាស់តំបន់ស្នូលទាំងនេះក្នុងកម្រិតអប្បបរមាប៉ុណ្ណោះ។ ប៉ុន្តែការស្រាវជ្រាវចម្រុះធ្វើឡើងដោយក្រុមការងារអង្គការ **IUCN** បានរកឃើញថាសហគមន៏មូលដ្ឋានពឹងផ្អែកយ៉ាងច្រើន លើធនធានធម្មជាតិនៅក្នុងតំបន់ស្នូលទាំងនេះ ដូច្នេះជាការបញ្ជាក់អំពីសារៈសំខាន់ដែលតម្រូវឱ្យធ្វើការវាយតម្លៃចម្រុះពេញលេញ ដោយប្រើប្រាស់ពហុជំនាញដែលផ្តោតលើ ការផ្តល់ព័ត៌មានពាក់ព័ន្ធអំពីទាំងការអភិរក្ស និងបញ្ហាសេដ្ឋកិច្ចសង្គម។

តាមរយៈគម្រោង **IUCN-Darwin** ការវាយតម្លៃចម្រុះមួយបានធ្វើឡើងនៅដើមឆ្នាំ ២០០៧ ដើម្បីប៉ាន់ប្រមាណអំពីផលប៉ះពាល់មកលើការចិញ្ចឹមជីវិតជីវៈចម្រុះ និងសេដ្ឋកិច្ចនៅមូលដ្ឋានបណ្តាលពីសំណើបែងចែកជាតំបន់គ្រប់គ្រងនេះ។ លទ្ធផលបង្ហាញថា ប្រសិនបើដាក់ឱ្យអនុវត្តសំណើផែនការបែងចែកតំបន់នោះនឹងមានឥទ្ធិពលអវិជ្ជមានមកលើសមាជិកក្រីក្រជាងគេក្នុងសហគមន៏នៅតំបន់រ៉ាមសារ ដែលរួមទាំងអ្នកតាំងទីលំនៅចល័តជនគ្មានដីធ្លី និងអ្នកដែលពឹងផ្អែកលើការនេសាទសម្រាប់ជាប្រភពប្រាក់ចំណូល និងសន្តិសុខស្បៀងផងដែរ។

យោងតាមលោក ម៉ាក ឌុយប័រ អ្នកជំនាញការខាងការចិញ្ចឹមជីវិត នៅក្នុងក្រុមការងារគម្រោងអង្គការ IUCN "អ្នកប្រើប្រាស់តំបន់ព្រះសាខន [ដែលស្មើជាតំបន់ស្នូល] ច្រើន

[1] សូមអានក្នុង : www.iucnredlist.org

ជាងគេ គឺជាអ្នកនេសាទក្រីក្រ ជាពិសេសពួកគេនេសាទត្រីរៀល នៅក្នុងរដូវត្រីទាំងនេះធ្វើចរាចរមក ពងកូន"។

លោក អាល់វីន ឡូប៉េ ប្រធានក្រុមវាយតម្លៃ និងជាអតីតអ្នក ជំនាញអេកូឡូស៊ីតំបន់ដីសើម សម្រាប់កម្មវិធីថ្នាក់តំបន់ស្តីពីការអភិរក្ស និងប្រើប្រាស់ជីវៈចម្រុះតំបន់ដីសើមទន្លេមេគង្គដោយនិរន្តរភាព(MWBP) និងលោក គង់ គីមស្រេង មន្ត្រីគម្រោងពីអង្គការ IUCN និងជាទីប្រឹក្សាផ្នែកជីវៈចម្រុះ នៅក្នុងក្រុមការងារអង្គការ IUCN បានបន្ថែមថា "ផ្នូកខ្សាច់នៅក្នុងតំបន់ព្រះសាខន" គឺជាកន្លែងធ្វើសំបុកសំខាន់មួយ សម្រាប់ពពួកសត្វរំពេទន្លេដែលរងការគំរាមកំហែង ចំណែកព្រៃនៅតាមផ្លូវទឹកតូចៗ មាននាទីជាទ្រនំ និង កន្លែងធ្វើសំបុកសម្រាប់ប្រភេទផ្សេងៗ ទៀតជាច្រើន ដូចជា ក្អែកទឹក និង ស្មោញ។

ដោយពិចារណាទិដ្ឋភាពទាំងបីបញ្ចូលគ្នា យើងបានពិនិត្យមើលជម្រើសសម្រាប់ការគ្រប់គ្រង និងបានរកឃើញដំណោះស្រាយ។ យើងបានរកឃើញថា រដូវកាលគឺជាកត្តាសំខាន់មួយ ទាក់ទងនឹងកាលវេលានៃការទាញយកធនធាន (ជាពិសេសត្រី) និងការប្រើប្រាស់ជាជម្រក សម្រាប់ជីវៈចម្រុះ និងជាកន្លែងសត្វធ្វើសំបុក។

ពេលធ្វើការបង្ហាញលទ្ធផលពីការវាយតម្លៃនេះនៅខេត្តស្ទឹងត្រែង ក្នុងខែកុម្ភៈ ឆ្នាំ ២០០៧ ដែលចូលរួមដោយមន្ត្រីថ្នាក់ស្រុក និងថ្នាក់ជាតិ ការសន្និដ្ឋានមួយបានធ្វើឡើងដោយស្នើដាក់តំបន់ព្រះសាខន ជាតំបន់ហាមឃាត់តាមរដូវដោយអនុញ្ញាតឱ្យប្រើប្រាស់នៅរដូវនេសាទត្រីរៀល ព្រោះថាវានឹងប៉ះពាល់តិចតួចដល់ជីវៈចម្រុះផ្សេងទៀតនៅរដូវនោះ។

កិច្ចប្រជុំពិគ្រោះយោបល់ក្រោយមកនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០៨ ជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បានកត់សំគាល់ថា ការអនុញ្ញាតឱ្យប្រជាជនចូលទៅក្នុងតំបន់ស្នូលព្រះសាខននឹងមានទំនាស់ជាមួយលក្ខណៈវិនិច្ឆ័យដែលចែងនៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងអាចផ្តល់ជាទម្លាប់អាក្រក់សម្រាប់តំបន់ស្នូលផ្សេងទៀត ដែលមានការហាមឃាត់ប្រជាជនពីការចេញចូលនិងទាញយកធនធាន។ ឯកឧត្តម **ចាយ សាមិត្ត** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានបានលើកឡើងថា បើព្រះសាខនជាទីជម្រកសំខាន់មួយទាំងសម្រាប់ជីវៈចម្រុះ និងការចិញ្ចឹមជីវិត គេគួរកំណត់វាជាតំបន់អភិរក្ស ឬតំបន់ប្រើប្រាស់ដោយនិរន្តរភាព។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ចែងពីការអនុញ្ញាតឱ្យចូល និងទាញយកធនធានពីក្នុងតំបន់អភិរក្ស និងតំបន់ប្រើប្រាស់ដោយនិរន្តរភាពតាមការកំណត់របស់ច្បាប់តំបន់ការពារធម្មជាតិ និងក្នុងករណីដែលមានការអនុញ្ញាតពីអាជ្ញាធរតំបន់ការពារធម្មជាតិ និង/ឬមានបទប្បញ្ញត្តិនិងកិច្ចព្រមព្រៀងរវាង សហគមន៍មូលដ្ឋាន និងអាជ្ញាធរតំបន់ការពារធម្មជាតិ។

សព្វថ្ងៃនេះ ការលំបាកខ្លាំងជាងមុនគឺការកំណត់ថាតើបទប្បញ្ញត្តិ ដែលមានស្រាប់សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិមានភាពទន់ភ្លន់គ្រប់គ្រាន់កម្រិតណាសម្រាប់ទទួលយកដំណោះស្រាយនេះ ដើម្បីការពារទាំងជីវៈចម្រុះនិងការចិញ្ចឹមជីវិត និងដើម្បីធានាថាមានការផ្តល់ធនធាន ដើម្បីអាចអនុវត្តផែនការគ្រប់គ្រងនៅក្នុងតំបន់រាមសារស្ទឹងត្រែង។

ឯកសារណែនាំ IWA បង្ហាញពីវិធីសាស្ត្រវាយតម្លៃចម្រុះលើជីវៈចម្រុះសេដ្ឋកិច្ច និងការចិញ្ចឹមជីវិត ដើម្បីពង្រឹងវិធាននានាដែលជួយកាត់បន្ថយភាពក្រីក្រតាមរយៈការអភិរក្សតំបន់ដីសើម។ ដោយផ្តោតលើដំណើរការ ជាងការណែនាំតាមជំហានទីមួយៗ ឯកសារណែនាំនេះ គូសបញ្ជាក់អំពីដំណើរការរៀបចំការត្រៀមលក្ខណៈ និងធ្វើការវាយតម្លៃចម្រុះ និងអធិប្បាយអំពីវិធីនានាសម្រាប់វិភាគ និងបង្ហាញព័ត៌មានដែលប្រមូលបានដោយប្រើប្រាស់ផែនទី **GIS** និងកម្រងទិន្នន័យអេឡិចត្រូនិក ដើម្បីធ្វើអត្តសញ្ញាណកន្លែងត្រួតគ្នារវាងតំបន់ដែលមានប្រភេទរងការគំរាមកំហែង និងដែលមនុស្សពឹងផ្អែកខ្លាំងក្លា។



រូបទី ១: វិធីសាស្ត្រ IWA ទទួលស្គាល់តម្លៃរាល់សមាសភាគនៃតំបន់ដីសើម





Fig. 1: The IWA approach values all components of a wetland

**THE INTEGRATED WETLAND ASSESSMENT (IWA) TOOLKIT**

The IWA Toolkit presents integrated biodiversity, economic and livelihood assessment methodologies to strengthen pro-poor approaches to wetland conservation. With an emphasis on process rather than step-by-step instruction, the Toolkit outlines the process of designing, preparation for, and undertaking an integrated assessment, and describes methods for analysing and presenting the information collected using GIS maps and electronic databases to identify spatial overlaps between areas of threatened species and high human dependence.

Developed through experience gained in undertaking the integrated assessments at Stung Treng, and on the floodplain of the Rufiji River in Tanzania, the Toolkit is intended to promote the conservation of wetlands in the face of competing developments by presenting information on the full value of the wetland to biodiversity and local livelihoods and economies.

The Toolkit is founded on the premise that an integrated approach to assessment is necessary in order to generate information that adequately addresses both conservation and socioeconomic considerations It must be practically useful, and policy relevant to wetland planning and management. As both wetland values and threats encompass biological, ecological, economic, and livelihood aspects, and wetland management responses must simultaneously address and react to each of these factors, a thorough understanding of all, and of the interlinkages and interconnectivity between them, is required.

The main components of integrated wetland assessment are seen as species and habitat-based biodiversity assessment, economic valuation, and livelihoods analysis. Maps and databases provide useful tools to bring together, represent, analyse and share the information that integrated assessments yield. Such assessments can inform both local and global conservation planning and action, and point to management and policy recommendations which simultaneously support biodiversity conservation, sustain local livelihoods, and reduce poverty.

The Toolkit describes a framework for assessment which consists of the following stages:-

- Defining management objectives: recognising and balancing both conservation and development goals, and promoting a pro-poor approach to wetland man agement, is a process that requires broad consultation and awareness of a wide range of issues. Developing a shared vision and rooting the assessment in real-world management goals and objectives are both essential to give purpose to the assessment process, and to identify relevant management and policy-related questions for the assessment;
- Assessment: documenting the distribution and status of wetland biodiversity, identifying the direct and indirect values of that biodiversity to local communities, and understanding past, current and future management and policy responses requires co-ordination of data collection, survey and review, across all relevant disciplines;
- Analysis and presentation: analysing data generated to provide clear management and policy recommen-dations which account for interlinkages and connectivity between biodiversity, economic and livelihood factors. Ensuring information is presented in a practical and policy-relevant format which is both appropriate and useful for planners and decision-makers in both conservation and development sectors.
- The guiding principles supporting this Toolkit are that wetland assessments should:
- Be integrated across disciplines and themes to present a comprehensive view of both the conservation and socioeconomic values of wetland ecosystems;
- Be geared to address a particular management issue or question;
- Generate information that can be used to support and improve the planning of on-the-ground wetland management, and provide information to make better decisions about how to use and allocate investment funds, land and resources in and around wetlands;
- Work to strengthen existing wetland management processes;
- Serve to sustain wetland values with a focus on ensuring peoples' continued equitable access to wetland goods and services, particularly for poorer and more vulnerable groups.

***This project has been funded by the UK government through the Darwin Initiative, which draws on the wealth of biodiversity expertise within the UK to help protect and enhance biodiversity around the world.***

## OVERVIEW

Wetlands have diverse and complex biological and socio-economic values that are often poorly reflected in conservation and development planning. Efforts to achieve sustainable, effective and equitable wetland conservation and management can be enhanced by a thorough understanding of the relationships between their biodiversity, economic, and livelihoods aspects; this requires that wetland assessments consider these dimensions in an integrated way. While there are techniques to assess wetland biological, economic and livelihood values and trends independently, there are a lack of practical methods to integrate the assessments, or to express this information in a way that contributes to real-world conservation and development planning.

IUCN (International Union for Conservation of Nature) and its partners have undertaken an integrated assessment of the economic, biodiversity and livelihood values of the Stung Treng Ramsar wetland on the Lower Mekong, Cambodia. The assessment aimed to collect relevant biodiversity and socio-economic data to inform the Ramsar Site management planning process that was underway in Cambodia. The assessment was undertaken as part of the international project Strengthening pro-poor wetland conservation using integrated biodiversity and livelihood assessment, which commenced in October 2005 and concludes in December 2008 The project is funded by the UK Darwin Initiative, with the aim of developing and testing an integrated multi-disciplinary wetland assessment Toolkit.

## STUNG TRENG RAMSAR SITE INTEGRATED ASSESSMENT

Upon entering Cambodia from the Khone Falls in Lao PDR, the Mekong River transforms into a majestic braided formation with a unique combination of flooded forests, bushlands, islands with sand and pebbles, fast flowing rapids, whirlpools, and deep pools. Designated as a Ramsar wetland of international importance on 23 October 1999, it hosts a range of IUCN Red List[1] threatened species, including the White-shouldered Ibis, River Terns, Siamese Crocodile, numerous fish species, and the Mekong River Irrawaddy Dolphin.

In 2006, ecological assessments in the Stung Treng Ramsar Site led to a proposal for the creation of a zoning plan for the site which includes a number of Core Zones where fishing and other activities of local communities would be banned. The recommendations were largely based on a biodiversity conservation perspective, concluding that there was currently minimal use of these exclusion zones by local people. The integrated research by the IUCN team has, however, revealed extensive reliance by the local communities on natural resources from within the proposed Core Zones, thus emphasising the importance of conducting fully integrated multidisciplinary assessments where the focus is on provision of information relevant to both species conservation and socio-economic issues.

In early 2007, through the IUCN-Darwin project, an integrated assessment was conducted to evaluate the potential impacts of the proposed zoning on livelihoods, biodiversity and local economies. The results revealed that the proposed zoning plans, if enforced, would adversely affect the poorest members of communities within the Ramsar Site, including migrant settlers, the landless, and those depending on income and food security from fishing.

According to Mr. Mark Dubois, a livelihood specialist with the IUCN project team, "The main users of the Preah Sakhon area [proposed as one of the Core Zones] are poor fishers, especially targeting Trey Riel during their spawning migration".

Mr. Alvin Lopez, the assessment team leader and former Wetland Ecologist for the regional Mekong Wetland Biodiversity Conservation and Sustainable Use Programme (MWBP), and Mr. Kong Kim Sreng, IUCN Project Officer and biodiversity advisor with the IUCN team added "The sandbars within Preah Sakhon are one of the main nesting sites for the globally threatened River Tern, while the channel woodlands serve as roosting and nesting sites for a range of other species such as cormorants and darters".

Taking all three perspectives into consideration, management options were explored and solutions were reached. It was found that seasonality is an important factor with regard to the timing of resource exploitation (mainly fish) and use of biodiversity refugia and nesting sites in the area.

At a presentation of the assessment findings in Stung Treng in February 2007, attended by district and national stakeholders, the conclusion was reached that Preah Sakhon should be a semi-restricted zone with access permitted during the Trey Riel fishing period as there would be minimal impacts to other biodiversity at that time of year.

A subsequent consultation meeting held in February 2008 with the General Department for Administration of Conservation and Protection (GDANCP) noted that allowing people to enter the Preah Sakhon Core Zone would be in conflict with the criteria established by the Protected Area Law and might also set a precedent for other core zones where people have been prevented from entering and collecting resources. The general director of GDANCP, H.E Chay Samith, therefore recommended that, if Preah Sakhon is an important habitat for both biodiversity and livelihoods, the area be designated as a Conservation Zone or Sustainable Use Zone; the Protected Area Law provides for access and resource collection within Conservation Zones and Sustainable Use Zones, provided permission is granted by the protected area authority and/or there is supporting regulation and agreement between the local community and the protected area authority.

The greater challenge now is to determine whether existing regulations for protected area management are flexible enough to accept this solution for the protection of both biodiversity and livelihoods, and to ensure that the resources are made available to allow implementation of the management plan within the Stung Treng Ramsar site.

[1] See: www.iucnredlist.org



ដោយបង្កើតឡើងតាមរយៈបទពិសោធន៍ ដែលទទួលបាននៅ ក្នុងការវាយតម្លៃចម្រុះនៅខេត្តស្ទឹងត្រែង និងនៅទំនាបលិចទឹកនៃទន្លេ **Rufiji** ក្នុងប្រទេសតង់ហ្សានី ឯកសារណែនាំនេះមានគោលដៅជម្រុញ ការអភិរក្សតំបន់ដីសើម នៅចំពោះមុខនៃការប្រកួតប្រជែងខាងផ្នែកអភិវឌ្ឍន៍ ដោយបង្ហាញព័ត៌មាន អំពីតម្លៃទាំងមូលនៃតំបន់ដីសើមសម្រាប់ជីវៈចម្រុះ ការចិញ្ចឹមជីវិតក្នុងមូលដ្ឋាន និងសេដ្ឋកិច្ច ។

ឯកសារណែនាំនេះ រៀបរៀងឡើងដោយផ្អែកលើចំណុចដែលថា វិធានចម្រុះសម្រាប់ការវាយតម្លៃមានសារៈសំខាន់សម្រាប់ប្រមូលព័ត៌មាន ដែលអាចធ្វើការដោះស្រាយបានគ្រប់គ្រាន់ ទាំងការអភិរក្ស និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។ វាមានប្រយោជន៍ និងពាក់ព័ន្ធជាមួយគោលនយោបាយសម្រាប់កសាងផែនការ និងគ្រប់គ្រងតំបន់ដីសើម ។ ដោយសារទាំងគុណតម្លៃ និងការគំរាមកំហែងចំពោះតំបន់ដីសើម គ្របដណ្តប់លើទិដ្ឋភាពជីវសាស្ត្រអេកូឡូស៊ី សេដ្ឋកិច្ច និងការចិញ្ចឹមជីវិតទាំងមូល ហើយការគ្រប់គ្រងតំបន់ដីសើម ត្រូវតែដោះស្រាយនិងឆ្លើយតបព្រមគ្នាទៅនឹងកត្តានីមួយៗទាំងនេះ គេចាំបាច់ត្រូវយល់ដឹងបានពេញលេញអំពីចំណងទាក់ទង និងភាពតជាប់គ្នារវាងកត្តាទាំងនោះ ។

សមាសភាគចំបងៗនៃការវាយតម្លៃចម្រុះតំបន់ដីសើម ត្រូវបានគមើលឃើញថាជាការវាយតម្លៃអំពីប្រភេទ និងទីជម្រក ដោយផ្អែកលើការវាយតម្លៃអំពីជីវៈចម្រុះ ការវាយតម្លៃសេដ្ឋកិច្ច និងការវិភាគ អំពីការចិញ្ចឹមជីវិត ។ ផែនទី និងកម្រងទិន្នន័យផ្តល់ជាឧបករណ៏ដ៏មានប្រយោជន៏សម្រាប់ប្រមូលផ្តុំ បង្ហាញ វិភាគ និងចែករម្លែកព័ត៌មាន ដែលបានពីការវាយតម្លៃចម្រុះនេះ ។ ការវាយតម្លៃបែបនេះ ជួយដល់ទាំងការកសាងផែនការ និងចំណាត់ការអភិរក្សនៅថ្នាក់មូលដ្ឋាន និង កម្រិតពិភពលោក និងចង្អុលបង្ហាញអំពីការគ្រប់គ្រង និងអនុសាសន៏ខាងគោលនយោបាយដែលគាំទ្រដល់ការអភិរក្សជីវៈចម្រុះ ទ្រទ្រង់ដល់ការចិញ្ចឹមជីវិតនៅមូលដ្ឋាន និងការបន្ថយភាពក្រីក្រ ។

ឯកសារណែនាំនេះអធិប្បាយអំពីក្របខ័ណ្ឌមួយសម្រាប់វាយ តម្លៃដែលផ្សំដោយជំហាននានាដូចតទៅ :

- **ការកំណត់គោលបំណងនានានៃការគ្រប់គ្រង:** ការទទួលស្គាល់ និងធ្វើឱ្យមានតុល្យភាពរវាងទាំងគោលដៅអភិរក្ស និងអភិវឌ្ឍន៏ និង ជម្រុញវិធានកាត់បន្ថយភាពក្រីក្រ តាមរយៈការគ្រប់គ្រងតំបន់ដីសើម គឺជាដំណើរការមួយ ដែលទាមទារឱ្យមានការពិគ្រោះយោបល់ទូលំទូលាយ និងការយល់ដឹងអំពីបញ្ហាជាច្រើនបែប ។ ការបង្កើតចក្ខុវិស័យរួម និងពិនិត្យមើលឫសគល់នៃការវាយតម្លៃ នៅក្នុងគោលដៅ និង គោលបំណងនានាជាក់ស្តែងនៃការគ្រប់គ្រង សុទ្ធតែមានសារៈសំខាន់សម្រាប់កម្មវត្ថុនៃដំណើរ ការវាយតម្លៃនេះ និងដើម្បីធ្វើអត្តសញ្ញាណ ចំណោទនានា ដែលទាក់ទងនឹងការគ្រប់គ្រង និងគោលនយោបាយសម្រាប់ការវាយតម្លៃនេះ ។
- **ការវាយតម្លៃ :** ការចងក្រងជាឯកសារអំពីរបាយ និងស្ថានភាពនៃជីវៈចម្រុះក្នុងតំបន់ដីសើម ការធ្វើអត្តសញ្ញាណគុណតម្លៃផ្ទាល់ និង ប្រយោលនៃជីវៈចម្រុះទាំងនោះសម្រាប់សហគមន៏នៅមូលដ្ឋាន និង ស្វែងយល់អំពីការគ្រប់គ្រង និងការឆ្លើយតបខាងគោលនយោបាយ កាលពីអតីតកាល សព្វថ្ងៃនិងទៅអនាគត ទាមទារឱ្យមានការសម្របសម្រួលលើការប្រមូលទិន្នន័យការអង្កេត និងពិនិត្យមើលនៅទូទាំង មុខជំនាញពាក់ព័ន្ធទាំងអស់ ។
- **ការវិភាគ និងការបង្ហាញៈ** ការវិភាគទិន្នន័យ ដែលប្រមូលបានផ្តល់ជាអនុសាសន៏ច្បាស់លាស់សម្រាប់ការគ្រប់គ្រង និងការកសាងគោលនយោបាយដែលគិតគូរអំពីចំណងទាក់ទង និងភាពតជាប់គ្នារវាងជីវៈចម្រុះសេដ្ឋកិច្ច និងការចិញ្ចឹមជីវិត ។ ការធានាថា ព័ត៌មានត្រូវបានរៀបចំតាមទម្រង់ងាយស្រួល និងពាក់ព័ន្ធជាមួយគោលនយោបាយដែលសមស្រប និងមានប្រយោជន៏ទាំងសម្រាប់អ្នកកសាងគោលនយោបាយនិងអ្នកធ្វើសេចក្តីសម្រេចក្នុងវិស័យអភិរក្ស និងវិស័យអភិវឌ្ឍន៏ ។

**គោលការណ៏ដែលទ្រទ្រង់ដល់ការរៀបរៀងឯកសារណែនាំនេះ ស្ថិតនៅត្រង់ថា ការវាយតម្លៃតំបន់ដីសើមគួរតែ :**

- ត្រូវដាក់បញ្ចូលនៅក្នុងមុខជំនាញ និងប្រធានបទនានា ដើម្បីបង្ហាញឱ្យឃើញទិដ្ឋភាពពេញលេញមួយនៃទាំងការអភិរក្សនិងតម្លៃសេដ្ឋកិច្ចសង្គមនៃប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើម ។
- ពង្រឹងដំណោះស្រាយបញ្ហានិងចំណោទនៃការគ្រប់គ្រងជាក់លាក់ ។
- ប្រមូលផ្តុំព័ត៌មានដែលអាចប្រើប្រាស់សម្រាប់ទ្រទ្រង់ និងកែលម្អដល់ដំណើរការកសាង ផែនការគ្រប់គ្រងនៅនឹងមូលដ្ឋាន និងផ្តល់ព័ត៌មានសម្រាប់ធ្វើការសម្រេចបានប្រសើរជាងមុនអំពីរបៀបប្រើប្រាស់ និងបែងចែកមូល និធិសម្រាប់វិនិយោគ ដីធ្លី និងធនធាន

នៅក្នុង និងនៅជុំវិញតំបន់ដីសើមនានា។

- ធ្វើការពង្រឹងដំណើរដែលមានស្រាប់ដើម្បីគ្រប់គ្រងតំបន់ដីសើម។
- ជួយថែរក្សាតម្លៃនៃតំបន់ដីសើមដោយផ្តោតលើការធានាថា ប្រជាពលរដ្ឋនៅតែបន្តមានលទ្ធភាពប្រើប្រាស់ផលិតផល និងសេវាពីតំបន់ដីសើមដោយសមធម៌ ជាពិសេស សម្រាប់ក្រុមអ្នកក្រីក្រ និងងាយ រងគ្រោះជាងគេ។

## សំណើដាក់ឱ្យប្រើប្រាស់ឯកសារណែនាំនេះនៅក្នុងប្រទេសកម្ពុជា

កិច្ចផ្តួចផ្តើម **Darwin** ផ្តល់មូលនិធិសម្រាប់ដំណាក់កាលក្រោយគម្រោងដល់គម្រោងមួយចំនួនតូចដែលមានជោគជ័យ "ដើម្បីបង្កើនលទ្ធផលបន្ថែម និងពង្រឹងឥទ្ធិពល និងស្នាដៃនៃគម្រោងទាំងនោះ"។ យើងកំពុងជម្រុញការវាយតម្លៃ និងគ្រប់គ្រងតំបន់ដីសើមជាបន្ថែមទៀត នៅកម្ពុជាតាមរយៈការប្រើប្រាស់មូលនិធិក្រោយគម្រោងដើម្បីទ្រទ្រង់គម្រោងរយៈពេលមួយឆ្នាំការវាយតម្លៃចម្រុះតំបន់ដីសើម សម្រាប់កែលម្អគោលនយោបាយ និងការអនុវត្ត : ពង្រីកការប្រើប្រាស់ ឯកសារណែនាំ **Darwin** នៅកម្ពុជា។

ប្រសិនបើបានជោគជ័យ យើងនឹងធ្វើការជាមួយ **NGOs** និងនាយកដ្ឋានពាក់ព័ន្ធរបស់រដ្ឋាភិបាល ដើម្បីកសាងសមត្ថភាពនៅកម្ពុជា អំពីការវាយតម្លៃចម្រុះតំបន់ដីសើម និងធ្វើការវាយតម្លៃជាបន្ទុសម្រាប់តំបន់ដីសើមដែលមានអាទិភាពខ្ពស់នៅកម្ពុជា។




រូបទី ២: ជំនួយដល់ការអភិរក្ស និងការអភិវឌ្ឍចម្រុះ (ICAD) តាមរយៈការវាយតម្លៃចម្រុះ (Source: Darwin Toolkit)

## អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ

ឯកសារណែនាំ **IWA** នឹងមានសម្រាប់ការចែកផ្សាយនៅខែធ្នូ ឆ្នាំ ២០០៨។ ចំពោះព័ត៌មានបន្ថែមអំពីការវាយតម្លៃចម្រុះនៅខេត្ត ស្ទឹងត្រែង ឬគម្រោងកិច្ចផ្តួចផ្តើម **Darwin** សូមទាក់ទង"

**លោក គង់ គីមស្រេង**
មន្ត្រីសម្របសម្រួលគម្រោង **Darwin** អង្គការ **IUCN** នៅកម្ពុជា
ផ្ទះលេខ ១៩ ផ្លូវលេខ ៣១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
ប្រអប់សំបុត្រលេខ ១៥០៤ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : +៨៥៥ (០២៣) ២២២ ៣១១
ទូរសារ : +៨៥៥ (០២៣) ២២២ ៣១២
អ៊ីម៉ែល : kksreng@iucncambodia.org

**Dr. William Darwall**
Manager, Freshwater Biodiversity Unit
IUCN Species Programme
219c Huntingdon Road
Cambridge CB3 0DL
UK
Tel: +44 1223 277966
Fax: +44 1223 277845
E-mail: william.darwall@iucn.org



IUCN

# INTEGRATED ASSESSMENT OF WETLANDS IN CAMBODIA

## Experience from Stung Treng Ramsar Site, Cambodia

Prepared by David Allen, Kong Kim Sreng, William Darwall and Oliver Springate-Baginski



POLICY BRIEF No. 2

SSC Species Survival Commission ODG DEV DARWIN INITIATIVE